# ភាសាបាលី និង ភាសាសំស្ក្រឹត

នៅប្រទេសឥណ្ឌា ភាសាមានទាំងអស់ចំនួន៨៤៥ ឯភាសាធំនិងសំខាន់មានចំនួន១៤ភាសាដែលក្នុងនោះមានភាសាបាលីនិងភាសាសំស្ក្រឹតផងដែរ ។ ភាសាខ្មែរយើងបានលាយចម្រុះដោយភាសាបាលីនិងភាសាសំស្ក្រឹតចំនួន៤០ភាគរយ ។ ភាសាបាលីមិនមែនជាភាសាសំស្ក្រឹតទេ ។ ភាសាសំស្ក្រឹតជាភាសាដើមដំបូងបំផុតនៃប្រទេសឥណ្ឌាសម័យបុរាណដែលមានរបៀបវេយ្យាករណ៍ទៀងទាត់ល្អណាស់ ។ ភាសាបាលីជាភាសារបស់អ្នកស្រុកក្នុងដែនមគធៈ ។ ពិតមែនតែភាសាបាលីកើតក្រោយភាសាសំស្ក្រឹត តែភាសាទាំងពីរនេះមានលក្ខណៈដូចគ្នាបេះបិទ ។ គេថា ភាសាសំស្ក្រឹតទុកដូចជាមាតាឬជាបងបង្កើតនៃភាសាបាលីព្រោះរបៀបវេយ្យាករណ៍ភាសាបាលីប្រើអនុលោមតាមភាសាសំស្ក្រឹតស្ទើរតែទាំងអស់ ។ ដើមឡើយនៅប្រទេសឥណ្ឌាទាំងមូល ប្រជាជនជម្ពូទ្វីបនិយមរាប់អានភាសាសំស្ក្រឹតណាស់ តែចាប់តាំងពីព្រះសម្មាសម្ពុទ្ធបានយកភាសាបាលីមកប្រកាសផ្សាយព្រះធម៌មក ភាសានេះក៏ទទួលការនិយមរាប់អានព្រមទាំងមានរស្មីលើសលប់ជាងភាសាទាំងឡាយ ។ ក្រោយពុទ្ធបរិនិព្វានរហូតដល់សព្វថ្ងៃ ព្រះពុទ្ធសាសនាហីនយាននៅតែរក្សាការប្រើប្រាស់ភាសាបាលីសម្រាប់ការប្រកាសផ្សាយព្រះធម៌ពុំដែលអាក់ខានឡើយ ។ សង្គាយនាព្រះធម៌សំខាន់ៗចំនួន៣ដងនៅជម្ពូទ្វីបនិង៣ដងនៅសិរីលង្កាដែលឆ្លងកាត់តាមព្រឹត្តិការណ៍ធំៗចំនួន៣គឺការប្រកាសផ្សាយព្រះធម៌ក្នុងពិភពលោកដោយព្រះបាទអសោកមហារាជ ការចារឹកព្រះពុទ្ធវចនៈឡើងកាន់គម្ពីរក្បួនខ្នាតព្រះត្រៃបិដកនៅពេលធ្វើសង្គាយនាទី៥ដោយព្រះភិក្ខុសង្ឃលង្កាចំនួន១០០០អង្គ និងសកម្មភាពទាំងឡាយរបស់ព្រះពុទ្ធឃោសាចារ្យនៅសិរីលង្កាដែលបានផ្ទៀងផ្ទាត់រៀបចំសម្រួលព្រះត្រៃបិដកឱ្យមានភាពបរិសុទ្ធដូចដើមឡើងវិញ សុទ្ធតែប្រើប្រាស់ដោយភាសាបាលីទាំងអស់ ។ នៅប្រទេសខ្មែរ មុនសម័យអង្គរនិងក្នុងសម័យអង្គរ សាសនាព្រាហ្មណ៍និងព្រះពុទ្ធសាសនាមហាយានប្រើភាសាសំស្ក្រឹតបានផ្សាយឥទ្ធិពលយ៉ាងខ្លាំងទៅលើជីវភាពនិងចិត្តគំនិតខ្មែរគ្រប់រូបដែលពេលនោះ ភាសាសំស្ក្រឹតបានក្លាយជាភាសាសំខាន់ហើយគេចាត់ទុកជាភាសាជាន់ខ្ពស់ ជាភាសារបស់បណ្ឌិតអ្នកប្រាជ្ញសប្បុរស ។ គេឃើញសិលាចារឹកបុរាណទាំងឡាយច្រើនតែចារជាភាសាសំស្ក្រឹតដូចជាសិលាចារឹកដែលមានចំណាស់ជាងគេឈ្មោះសិលាចារឹកវ៉ូកាញនៅគ្រឹស្តសតវត្សទី២ឬទី៣ ។ នៅសម័យក្រោយអង្គរ ព្រះពុទ្ធសាសនាហីនយានដែលនាំមកពីលង្កាបានចម្រើនលូតលាស់យ៉ាងខ្លាំងហើយមានជោគជ័យលើសាសនាព្រាហ្មណ៍និងព្រះពុទ្ធសាសនាមហាយាន ។ ឯភាសាបាលីដែលប្រើក្នុងព្រះពុទ្ធសាសនាហីនយាននេះក៏បានចូលមកជំនួសភាសាសំស្ក្រឹតវិញម្តង ។ សង្គមខ្មែរយើងបានឱ្យតម្លៃភាសាបាលីថាជាភាសាខ្ពង់ខ្ពស់ស្មើនឹងពាក្យទេសនារបស់ព្រះសម្មាសម្ពុទ្ធ ឬពាក្យប្រៀនប្រដៅរបស់ព្រះអង្គ ឬព្រះធម៌ ឬព្រះត្រៃបិដកទាំងមូល ។ រៀនបាលី មានន័យថា រៀនព្រះ

ពុទ្ធសាសនា ឬរៀនព្រះពុទ្ធវចនៈ ឬរៀនព្រះធម៌ ឬរៀនព្រះត្រៃបិដក ។ បណ្ឌិតអ្នកចេះស្ទាត់ជំនាញខាងផ្នែកព្រះពុទ្ធសាសនា គឺសំដៅយកអ្នកចេះភាសាបាលីនេះឯង ។

តើ បាលីភាសា មានន័យស្មើនឹងព្រះធម៌ ឬព្រះពុទ្ធវចនៈ ឬព្រះត្រៃបិដក មែនឬទេ ?

ក្រោយពីចប់វស្សាទី១នៅព្រៃឥសិបតនមិគទាយវ័នមក ព្រះសម្មាសម្ពុទ្ធទ្រង់បានបញ្ជូនព្រះអរហន្តចំនួន ៦០អង្គឱ្យទៅប្រកាសផ្សាយព្រះធម៌គ្រប់ទិសទាំងអស់ក្នុងដែនជម្ពូទ្វីបទាំងមូល ចំណែកព្រះពុទ្ធអង្គផ្ទាល់ទ្រង់យាងសំដៅទៅក្រុងរាជគ្រឹះជារាជធានីនៃមគធរដ្ឋរបស់ព្រះបាទពិម្ពិសារ ។ នៅសម័យនោះ មគធរដ្ឋជារដ្ឋពូកែមានអំណាច សម្បូរពោរពាសដោយភោគផលធម្មជាតិនិងប្រជាជនយ៉ាងច្រើនកុះករ ជាទីប្រជុំនៃអ្នកប្រាជ្ញបណ្ឌិតរាជបុរោហិត គ្រហ្ម៍គហបតីសេដ្ឋីមហាសាលនិងមេលទ្ធិសាសនាល្បីឈ្មោះបោះសម្លេងជាច្រើនរូប ។ ព្រះសម្មាសម្ពុទ្ធទ្រង់មានព្រះតម្រិះថា បើប្រជាជនមគធរដ្ឋមានព្រះបាទពិម្ពិសារនិងមេគណៈសាសនាធំៗជាដើមមានជំនឿលើព្រះអង្គហើយ ធម្មចក្កដែលជាកង់នៃធម៌របស់ព្រះអង្គនឹងមានដំណើររំលទៅបានស្រួលក្នុងដែនជម្ពូទ្វីបទាំងមូលដោយសារតែជំនួយរបស់អ្នកទាំងអស់នោះ ។ នេះហើយជាបុព្វហេតុដែលធ្វើឱ្យព្រះសម្មាសម្ពុទ្ធទ្រង់យកភាសាបាលីរបស់មគធរដ្ឋមកប្រើជាយានសម្រាប់ប្រកាសផ្សាយព្រះធម៌ជាដំបូងបង្អស់ ។ ដូច្នេះព្រះសម្មាសម្ពុទ្ធព្រះអង្គគ្រាន់តែយកភាសាបាលីឬមគធភាសាសម្រាប់ទេសនាផ្សាយព្រះធម៌ឱ្យអ្នកមគធរដ្ឋស្តាប់ប៉ុណ្ណោះ ពុំមែនព្រះអង្គចាត់ទុកថា ភាសាបាលីឬបាលីភាសា ឬមគធភាសា ជាព្រះធម៌ ជាព្រះពុទ្ធសាសនា ឬជាព្រះត្រៃបិដកទេ ។ ព្រះធម៌ឬព្រះពុទ្ធសាសនាអាចទេសនានិយាយពន្យល់ធ្វើអត្ថាធិប្បាយរែកញែកជាភាសាអ្វីដទៃទៀតក៏បានឥតទាស់ឱ្យតែត្រឹមត្រូវតាមផ្លូវធម៌ដែលហៅថា មជ្ឈិមាបដិបទា ។ ត្រង់នេះព្រះសម្មាសម្ពុទ្ធទ្រង់បានបញ្ជាក់យ៉ាងច្បាស់លាស់រួចអស់ហើយចំពោះព្រះមាតាចិញ្ចឹមមហាបជាបតិគោតមីថា ធម៌ណាប្រព្រឹត្តទៅដើម្បី (សេចក្តីតម្រេក ប្រកបដោយទុក្ខ សន្សំកិលេស ប្រាថ្នាធំ មិនសន្តោសចំពោះរបស់តាមមានតាមបាន ច្រឡូកច្រឡំដោយពួកដោយគណៈ សេចក្តីខ្ជិលច្រអូស គេចិញ្ចឹមក្រ) ធម៌ទាំងអស់នេះគប្បីដឹងថា មិនមែនជាធម៌ជាវិន័យ មិនមែនជាពាក្យប្រៀនប្រដៅរបស់តថាគតទេ ៕